# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៧)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្ដីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jun-21, 13:47
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សំណើរបស់ មាស មុត សុំពន្យារពេលចម្លើយរបស់ខ្លួន តបទៅនឹងសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យមិនបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការ នីតិវិធីក្នុងសំណុំរឿង ០០៣

---

**ដាក់ដោយ** ÷

**សហមេធាវី** ៖

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន** ÷

**ចៅក្រមអង្គបុរេជំនុំជម្រះ** ៖

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ផុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដី ០០៣**

លោក មាស មុត តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) តាមរយៈនេះ ស្នើសុំពន្យារពេលចំនួន ប្រាំថ្ងៃ សម្រាប់ចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ (“សំណើរបស់ ស.ព.អ.”)[1]។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ដើម្បីឆ្លើយតបឱ្យបានត្រឹមត្រូវ និង ទូលំទូលាយ ទៅនឹងបញ្ហាដ៏ស្មុគស្មាញនានា ដែល ស.ព.អ. បានលើកឡើង ដោយផ្អែកលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ (“អ.ប.ជ.”)[2]។

## I. ច្បាប់ និងឧទ្ធិករណ៍

១. លោក មាស មុត មានសិទ្ធិក្នុងការឆ្លើយតបដោយប្រសិទ្ធភាព[3]។ ជាទូទៅ នេះមានន័យថា គាត់ត្រូវទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និង មានសហមេធាវីដែល

[1] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D271/1.1។ សំណើរបស់ ស.ព.អ. នេះ ត្រូវបានជូនដំណឹងទៅមេធាវីការពារក្តីកាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២១ ដូច្នេះ កាលបរិច្ឆេទកំណត់ដើម្បីដាក់ចម្លើយ គឺត្រឹមថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០២១ អនុលោមតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក.។ *សូមមើល* ការជូនដំណឹងរបស់មន្ត្រីគ្រប់គ្រងសំណុំរឿង “[ដែលបានដាក់ដោយ ក.ស.ព] ឯកសារថ្មី៖ សំណុំរឿង ០០៣ (សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣” ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១។

[2] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ ឯកសារ D266/27 និង D267/35 (“សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣”)

[3] រដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខណ្ឌច្បាប់ អ.វ.ត.ក. ដែលដាក់បញ្ចូលបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធានាថា ជនត្រូវចោទ និង ជនជាប់ចោទ ត្រូវបានផ្តល់ឱកាសឱ្យដាក់សារណា*ប្រកបដោយប្រសិទ្ធភាព*។ *សូមមើល* មាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលបានកែប្រែដោយព្រះរាជក្រម ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើវិសោធនកម្ម មាត្រា ១១, ១២, ១៣, ១៨, ២២, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ ព្រមទាំងមាត្រាផ្សេងៗទៀត ពីជំពូក ៨ ដល់ជំពូក ១៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ (“រដ្ឋធម្មនុញ្ញកម្ពុជា”)។ មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ ថ្មី និងមាត្រា ៣៥ ថ្មី (ខ), (ឃ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(៣)(ខ), (ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានអនុម័តនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ បានចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦, ឯកសារលេខ 999 U.N.T.S. 171 (“ICCPR”)។ *សូមមើលផងដែរ រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៨ ឯកសារ

មានសមត្ថភាព ក្នុងការបំពេញកិច្ចគ្រប់យ៉ាងដោយយកចិត្តទុកដាក់ ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់[4]។ ជាពិសេស ក្នុងករណីនេះ មានន័យថា លោក មាស មុត ត្រូវទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ ដើម្បីដាក់ចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់ ស.ព.អ.។ ជាការគួរឲ្យកត់សម្គាល់ រយៈពេលកំណត់ចំនួន ដប់ថ្ងៃ សម្រាប់ការរៀបចំចម្លើយ ដូចមានចែងនៅក្នុងមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត គឺតិចមែនទែនមិនអាចឲ្យលោក មាស មុត ធ្វើការឆ្លើយតបប្រកបដោយប្រសិទ្ធភាពបានទេ ដោយសារតែបញ្ហានានាដែល ស.ព.អ. បានលើកឡើងដោយផ្អែកលើសេចក្តីពិចារណារបស់ អ.ប.ជ មានលក្ខណៈស្មុគស្មាញ។

២. កិច្ចការដ៏សែនលំបាក ដែលមានរយៈពេលកំណត់ចំនួន ដប់ថ្ងៃ ត្រូវបានបង្ហាញឡើងជាចម្បង តាមរយៈបញ្ហាស្មុគស្មាញនានាដែល ស.ព.អ. បានលើកឡើង ដោយផ្អែកលើសេចក្តីពិចារណារបស់ អ.ប.ជ. និង ប្រភពឯកសារជាច្រើនប្រភេទ និង មានចំនួនច្រើន ដែលបានដកស្រង់នៅក្នុងសំណើរបស់ ស.ព.អ.៖

ក. *បញ្ហានានាដែលបានលើកឡើងនៅក្នុងសំណើរបស់ ស.ព.អ.៖* ផ្អែកលើការសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ. និង មតិយោបល់ដាច់ដោយឡែក ស.ព.អ. លើកឡើងនូវបញ្ហាផ្លូវច្បាប់យ៉ាងស្មុគស្មាញជាច្រើន រួមមាន ថាតើ៖ (i) អ.ប.ជ. មានកំហុសអង្គច្បាប់ និង “បណ្តាលឲ្យមានភាពអយុត្តិធម៌ជាក់ស្តែង” ដោយខកខានមិនបានធ្វើការសម្រេចជាចុង

---

D362/4 កថាខណ្ឌ ១០។ រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* សំណុំរឿងលេខ IT-08-91-A សេចក្តីសម្រេចលើញត្តិរបស់ Mićo Stanišić និង Stojan Župljanin សុំការផ្លាស់ប្តូរពេលវេលា និងចំនួនពាក្យកំណត់សម្រាប់ដាក់សារណាបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៣ ទំព័រ ២, ៤។ រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Sainović និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ IT-05-87-A សេចក្តីសម្រេចលើសំណើរួមសុំពន្យារពេល ដើម្បីដាក់សារណារបស់ចុងចោទ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៤។ រឿងក្តីរវាង *Marpa Zeeland B.V. & Metal Welding B.V. ទល់នឹង ប្រទេសហូឡង់* សំណុំរឿងលេខ ៤៦៣០០/៩៩ របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) ចុះថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ៥១។

[4] ការបំពេញកិច្ចប្រកបដោយការយកចិត្តទុកដាក់ តម្រូវឲ្យសហមេធាវីរបស់ជនត្រូវចោទធ្វើអ្វីមួយ និងគ្រប់យ៉ាងទាំងអស់ ដើម្បីធានាថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានផ្តល់ជូនយ៉ាងពេញលេញដល់កូនក្តីរបស់ខ្លួន រួមមាន ការធ្វើកិច្ចចាំបាច់ទាំងអស់ ទាក់ទងនឹងការជំទាស់តវ៉ាលើអង្គហេតុ និងអង្គច្បាប់ ការពិនិត្យមើលលើសច្ចសីលភាព និងភាពត្រឹមត្រូវនៃភស្តុតាង ដែលបានប្រមូលដោយសហចៅក្រមស៊ើបអង្កេត ដែលត្រូវបានយកមកប្រើប្រាស់ប្រឆាំងនឹងជនត្រូវចោទ ។ល។ និង ។ល។ វិធាន ១.៣ នៃវិធានអាឡាស្កានៃក្រមសីលធម៌វិជ្ជាជីវៈ (ALASKA RULES OF PROF'L CONDUCT) (បោះពុម្ពផ្សាយនៅឆ្នាំ ២០១៧-២០១៨) ។ *ដូចខាងលើ* អនុសាសន៍លើវិធាន ១.៣។ *សូមមើលផងដែរ* មាត្រា ៧ នៃក្រមសីលធម៌មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី (ឆ្នាំ ១៩៩៥) ។ វិធាន ២២(៤) នៃវិធានផ្ទៃក្នុង។

ក្រោយ "ដែលបិទបញ្ចប់ជាស្ថាពរនូវដំណាក់កាលមុនការជំនុំជម្រះលើសំណុំរឿង ០០៣ (និង ផលវិបាកនៃកំហុសអង្គច្បាប់នោះ)[5] (ii) អ.ប.ជ. បានសន្និដ្ឋានជាឯកច្ឆន្ទថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[6] (iii) អ.ប.ជ. ត្រូវបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ នៅពេលដែលចៅក្រមនៃ អ.បជ មិនបាន "ឈានដល់ការព្រមព្រៀងជារួមមួយចំពោះសេចក្តីសម្រេចចុងក្រោយ"[7] និង ជាជម្រើសម្យ៉ាងទៀត (iv) អ.ប.ជ. ត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅកាន់អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង[8]។

ខ. *ប្រភពឯកសារជាច្រើនប្រភេទ និងមានចំនួនច្រើន៖* ទោះបីជាប្រភពឯកសារជាច្រើនប្រភេទ និងមានចំនួនច្រើន ដែលបានដកស្រង់នៅក្នុងសំណើរបស់ ស.ព.អ. មិនចាំបាច់បង្ហាញឲ្យដឹងចំពោះទម្ងន់នៃទឡ្ហីករណ៍របស់លោកស្រីក៏ដោយ ក៏ប្រភពឯកសារទាំងនេះបង្ហាញអំពីភាពចាំបាច់ដែលមេធាវីការពារក្តីត្រូវធ្វើការស្រាវជ្រាវ និង វិភាគ ដើម្បីឆ្លើយតប។ សំណើរបស់ ស.ព.អ. ចំនួន ១៦ ទំព័រ មាន ៩៧ ជើងទំព័រ ដែលយោងទៅបញ្ជីសំអាងផ្លូវច្បាប់ចំនួន ៦៦ រួមមាន៖ (i) កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង និងក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក. (ii) ប្រវត្តិនីតិវិធីពាក់ព័ន្ធក្នុងរឿងក្តី ០០៣ (iii) យុត្តិសាស្ត្ររបស់ អ.វ.ត.ក. ពីរឿងក្តី ០០១, ០០២ និង ០០៤/២ (iv) លក្ខន្តិកៈ និងយុត្តិសាស្ត្រនានាពីតុលាការ*មិនអចិន្ត្រៃយ៍* តុលាការក្រោយសង្គ្រាមលោកលើកទីពីរ តុលាការយុត្តិធម៌អន្តរជាតិ និង តុលាការអន្តរជាតិសម្រាប់នីតិសមុទ្រ (v) ច្បាប់ជាតិពីសាធារណរដ្ឋអាហ្វ្រិកកណ្តាល និង បារាំង និង (vi) ឯកសារនានារបស់ អ.ស.ប.[9]។

៣. ដើម្បីបំពេញករណីយកិច្ចតាមបែបសីលធម៌ និងវិជ្ជាជីវៈរបស់ខ្លួន ប្រកបដោយការយកចិត្តទុកដាក់ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត[10] និង ធ្វើសេចក្តី

---

[5] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១២-១៧។

[6] *ដូចខាងលើ* កថាខណ្ឌ ១៨។

[7] *ដូចខាងលើ* កថាខណ្ឌ ១៨-២១។

[8] *ដូចខាងលើ* កថាខណ្ឌ ២២-៣១។

[9] បញ្ជីមូលដ្ឋាននៃសំអាងផ្លូវច្បាប់ប្រើប្រាស់ជាឯកសារយោងនៃសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D271/1.1។

[10] *សូមមើលខាងលើ* ជើងទំព័រ ៤។

ព្រាងចម្លើយប្រកបដោយប្រសិទ្ធភាព មេធាវីការពារក្តីត្រូវពិនិត្យ និង វិភាគរាល់ឯកសារសំអាង សំខាន់ៗ ដែលដកស្រង់ដោយចៅក្រមនៃ អ.ប.ជ. នៅក្នុងសេចក្តីពិចារណារបស់ខ្លួន និង ស.ព.អ. នៅក្នុងសំណើរបស់លោកស្រី ស្រាវជ្រាវច្បាប់ ពិនិត្យសំណុំរឿង សុំការណែនាំពីលោក មាស មុត ព្រមទាំងព្រាងទឡ្ហីករណ៍ដែលរឹងមាំសមហេតុផល។ កិច្ចការទាំងនេះ មិនអាចធ្វើទៅតាមបទដ្ឋានខ្ពស់បំផុត ដែលចាំបាច់ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត នៅក្នុងរយៈពេលកំណត់ចំនួន ១០ ថ្ងៃ អនុលោមតាមសេចក្តីណែនាំអនុវត្ត ដែលនៅក្រោមកាលៈទេសៈធម្មតា អាចគ្រប់គ្រាន់ក្នុងការឆ្លើយតបបានឡើយ។

៤. អនុលោមតាមវិធាន ៣៩(២) នៃវិធានផ្ទៃក្នុង អ.ប.ជ. មានសិទ្ធិអំណាច “កំណត់ពេលវេលា” សម្រាប់ដាក់សារណា “ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តី” និង អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង មានសិទ្ធិអំណាច “ពន្យារពេលវេលាកំណត់ដែលខ្លួនបានកំណត់”។ អ.ប.ជ ក៏មានឆន្ទានុសិទ្ធិផងដែរ ក្នុងការទទួលយកឯកសារនានា ដែលដាក់នៅក្រោយរយៈពេលកំណត់ជាធរមាន អនុលោមតាមមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្ត។

៥. ការស្នើសុំនេះ នឹងមិនពន្យារការបិទបញ្ចប់ដំណើរការនីតិវិធីមុនការជំនុំជម្រះ ដែលមេធាវីការពារក្តីក៏បានស្នើសុំផងដែរ នៅក្នុងសំណើរបស់ខ្លួន សុំឱ្យបិទបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ[11]។ ដោយសារតែការស៊ើបអង្កេតរយៈពេល ១៣ ឆ្នាំ និង កិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះ ស្ថានភាពមិនធ្លាប់កើតមានពីមុននៃដំណើរការនីតិវិធីទាំងនេះ ព្រមទាំងផលប៉ះពាល់នៃសេចក្តីសម្រេចរបស់ អ.ប.ជ. ទៅលើជោគវាសនារបស់លោក មាស មុត និង កេរដំណែលរបស់ អ.វ.ត.ក. ពេលវេលាបន្តិចបន្តួចដែលស្នើសុំបន្ថែមនេះ ចូលរួមចំណែកយ៉ាងច្រើនសម្បើមដល់ប្រយោជន៍យុត្តិធម៌ ដែលសមនឹងឱ្យ អ.ប.ជ. អនុវត្តឆន្ទានុសិទ្ធិដោយសមប្រកប ផ្តល់ការអនុញ្ញាតតាមការស្នើសុំដ៏សមរម្យ ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ផលប្រយោជន៍របស់លោក មាស មុត[12]។

៦. ពុំមានភាគីណានឹងត្រូវខូចប្រយោជន៍ពីការស្នើសុំនេះទេ ជាពិសេស ដោយសារតែមេធាវីការពារក្តីមិនជំទាស់ទៅនឹង ស.ព.អ. ដែលត្រូវទទួលបានការពន្យារពេលស្មើគ្នា ក្នុងការឆ្លើយតបទៅនឹង

[11] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងប័ណ្ណសារ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D272។

[12] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

សំណើរបស់មេធាវីការពារក្តី សុំឱ្យបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ[13]។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៥** ខែ**មិថុនា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្តីលោក មាស មុត**

| អាង ឧត្តម | Michael G. KARNAVA |
|---|---|

[13] ដោយសន្និតថា ដោយសារតែវិសាលភាព ទំហំ និង ភាពស្មុគស្មាញនៃបញ្ហាទាំងឡាយ ដែលលើកឡើងដោយមេធាវីការពារក្តីនៅក្នុងសំណើរបស់ខ្លួនសុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ លោកស្រីក៏គួរទទួលបានប្រយោជន៍ពីការពន្យារពេលដ៏សមរម្យដែរសម្រាប់ចម្លើយរបស់លោកស្រី។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាស្តីពីអនុភាពផ្លូវច្បាប់នៃសេចក្តីពិចារណារបស់ អ.ប.ជ. នៅក្នុងរឿងក្តី ០០៣ ទេ ដូច្នេះហើយ ក៏មិននាំឱ្យខូចប្រយោជន៍ ដោយសារការស្នើសុំនេះទេ។